# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២៨០ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណូមពររបស់សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១ :** បង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ដែលជាអង្គការកំពូលសម្រាប់ជុំនំជម្រះដោះស្រាយអធិករណ៍ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១-សម្ដេចព្រះពុទ្ធាចារ្យ | **ទួច សុខទោហោរ** | ប្រធាន |
| ២-ព្រះមហារាជធម្ម | **ចន្ទ្យ អានេតា** | អនុប្រធានទី១ |
| ៣-ព្រះមហាព្រហ្មមុនី | **គឹម សុផា** | អនុប្រធានទី២ |
| ៤-ព្រះអរិយវង្ស | **គង់ ច័ន្ទថុល** | សមាជិក |
| ៥-ព្រះធម្មវរោត្តម | **ទូច សាគរ** | សមាជិក |
| ៦-ព្រះវជិរមេធា | **ឡឿង ហាមុនី** | សមាជិក |
| ៧-ព្រះគ្រូមង្គលមុនី | **ឈិន ហាន** | សមាជិក |
| ៨-ព្រះគ្រូធម្មរាជចរិយា | **ខួន ស្ដេចតក្លី** | លេខាធិការ |
| ៩-ព្រះគ្រូទីបញ្ញាណមុនី | **ខេន ស៊ាខលី** | លេខាធិការរង ។ |

**មាត្រា ២ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ មានភារកិច្ចដូចខាងក្រោមៈ

- ជាសហធម្មិកសង្ឃជាន់ខ្ពស់របស់សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ដែលកើតមានឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ជំនុំជម្រះអធិករណ៍ដែលកើតមានឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលវិន័យធរ ធម្មធរ អនុគណ មេគណ គណៈសង្ឃនៃគណៈធម្មយុត្តិកនិកាយ មិនអាចរម្ងាប់បាន ។

- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវ ឈ្វេងយល់រកហេតុផលពិតប្រាកដអំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមកធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន ។
- រកគ្រប់វិធី ធ្វើការណែនាំ សម្របសម្រួលនូវភាគីបង្កអធិករណ៍ឲ្យយល់គ្នាដោយប្រើប្រាស់គ្រប់រូបភាពសិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល ។
- ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឲ្យភាគីនីមួយៗអាចទទួលយកបានដោយគ្មានការវង្វៀស ។
- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនៈគ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង៤ ។
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ឬក្រសួងធម្មការ និងសាសនា ប្រគល់ឲ្យពិនិត្យដោះស្រាយ ។
- ក្នុងការដោះស្រាយអធិករណ៍ត្រូវមានតំណាងមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅនឹងកន្លែងអធិករណ៍ ចូលរួមជាអ្នកពិគ្រោះយោបល់ និងអង្កេតការណ៍ក្នុងការដោះស្រាយរម្ងាប់អធិករណ៍នោះ ។
- ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ត្រូវធ្វើរបាយការណ៍អំពីករណីអធិករណ៍ និងករណីបានជំនុំជម្រះដោះស្រាយអធិករណ៍នីមួយៗ បញ្ជូនមកសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ និងក្រសួងធម្មការ និងសាសនា ដើម្បីមានមុខការបន្ត ។

**មាត្រា ៣ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ត្រូវរៀបចំលេខាធិការដ្ឋានមួយដឹកនាំដោយព្រះប្រធាន ០១ រូប និងមានសមាជិកមួយចំនួនជាជំនួយការ តាមការចាំបាច់ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា ។

**មាត្រា ៤ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ដំណើរការ ។

**មាត្រា ៥ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ គ្រប់រាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**មិន ឃិន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ